# សេចក្តីណែនាំចំពោះការប្រើប្រាស់កូដប្រភព CITES

**បោះពុម្ពលើកទីមួយ ខែកុម្ភៈ ឆ្នាំ២០១៧**
**រៀបចំក្រោមកិច្ចសន្យារបស់លេខាធិការដ្ឋាន CITES ដោយសហភាពអន្តរជាតិដើម្បីការអភិរក្សធម្មជាតិ (IUCN), ដែលមានទីតាំងនៅ Rue Mauverney 28, 1196 Gland, ប្រទេសស្វីស។**

**និពន្ធដោយ Jessica A. Lyons, Daniel J. D. Natusch និង Robert W. G. Jenkins**

**ផលិតដោយមានការគាំទ្រហិរញ្ញវត្ថុពីសហភាពអឺរ៉ុប**

**ការផលិតឡើងវិញនៃឯកសារនេះសម្រាប់គោលបំណអប់រំ ឬគោលបំណងដែលមិនពាក់ព័ន្ធនឹងអាជីវកម្ម គឺទទួលបានការអនុញ្ញាតដោយមិនចាំបាច់សុំការអនុញ្ញាតពីម្ចាស់កម្មសិទ្ធិនិពន្ធជាមុន។**

**ការផលិតឡើងវិញសម្រាប់លក់បន្ត ឬសម្រាប់គោលបំណងអាជីវកម្មផ្សេងៗតាមមធ្យោបាយណាក៏ដោយ មិនថាដោយថតរូប តាមប្រព័ន្ធអេឡិកត្រូនិក ធ្វើដោយដៃផ្ទាល់ដោយរួមមានដូចជាតាមម៉ាស៊ីនថតចម្លង ថតសម្លេង ឬទុកព័ត៌មាន និងក្នុងប្រព័ន្ធទិន្នន័យ ត្រូវបានហាមឃាត់ បើគ្មានលិខិតអនុញ្ញាតជាមុនពីម្ចាស់កម្មសិទ្ធិ។**

**ការជ្រើសរើសទីតាំងដែលមានចែងក្នុងសៀវភៅនេះ មិនបានបង្ហាញពីការសម្តែងមតិអ្វីមួយ មិនថាលើផ្នែកណា មួយរបស់អ្នកចងក្រងឬលេខាធិការដ្ឋាន CITES ចំពោះស្ថានភាពស្របច្បាប់របស់ប្រទេសណាមួយ ដែនដី ឬតំបន់ ឬទាក់ទងទៅនឹងការកំណត់ព្រំដែនរបស់វានោះទេ។**

**លេខាធិការដ្ឋាន CITES**
**Maison internationale de l'environnement**
**Chemin des Anémones**
**CH-1219 Châtelaine, ទីក្រុងហ្សឺណែវ**
**ប្រទេសស្វីស**

**ទូរស័ព្ទលេខ: +41 (0) 22 917 8139/40**
**លេខហ្វាក់: +41 (0) 22 797 34 17**
**អ៊ីម៉េល: info@cites.org**
**វេបសាយ: www.cites.org**

# 1.0 ប្រវត្តិ និងសេចក្តីផ្តើម

តួនាទីនៃអនុសញ្ញាស្តីពីពាណិជ្ជកម្មអន្តរជាតិលើសត្វព្រៃជិតផុតពូជ របស់អង្គការសត្វព្រៃនិងរុក្ខជាតិអន្តរជាតិ (Fauna and Flora (CITES)) គឺដើម្បីបញ្ញត្តិពាណិជ្ជកម្មអន្តរជាតិចំពោះសត្វនិងដើមឈើដែលមានចែងក្នុង CITES ដើម្បីធានាពីការរស់រានរបស់វានៅក្នុងព្រៃនឹងមិនមានការគម្រាមកំហែង។ ដើម្បីទទួលបានជោគជ័យ វាពិតជាសំខាន់ណាស់ដែលប្រព័ន្ធគ្រប់គ្រងប្រើប្រាស់ក្នុងការផលិតសត្វសម្រាប់ពាណិជ្ជកម្មអន្តរជាតិត្រូវកំណត់អោយច្បាស់និងបានយល់ ហើយរបបនិមួយៗមានឥទ្ធិពលមកកាន់ចំនួនសត្វព្រៃ ដែលត្រូវបានគេត្រួតពិនិត្យយ៉ាងសមស្រប។ ប្រព័ន្ធនិមួយៗគួរតែមានកូដប្រភពដែលពាក់ព័ន្ធដើម្បីប្រើលើលិខិតអនុញ្ញាត CITES និងវិញ្ញាបណ្ណប័ត្រដែលផ្តល់ជាដំណឹងដល់ភាគីពីប្រព័ន្ធគ្រប់គ្រងប្រើប្រាស់សម្រាប់បង្កើតពូជសត្វ ហើយហេតុដូច្នេះ បញ្ញត្តិនៃអនុសញ្ញាត្រូវបានគេយកមកអនុវត្ត។ ឧទាហរណ៍ សត្វមួយបានកើតនៅក្នុងព្រៃ មានកូដប្រភព "W" ដែលតំណាងអោយ Wild។ មានកូដប្រភពចំនួន១០ដែលគេកំពុងប្រើដើម្បីបញ្ជាក់ពីដើមកំណើតនៃពូជសត្វ ដែល មានក្នុងបញ្ជីពាណិជ្ជកម្ម CITES (ដូចមានពន្យល់លម្អិតក្នុងផ្នែក ២.០)។

ដើម្បីជាជំនួយដល់ភាគីជាមួយនឹងកិច្ចការអនុវត្តដាក់កូដប្រភពអោយបានត្រឹមត្រូវសម្រាប់នាំពូជសត្វ CITEs ចេញនោះ សេចក្តីសម្រេច ១៥.៥២ ពីការប្រជុំលើកទី១៥នៃសន្និសិទ CITES នៃភាគី (នៅ Doha, Qatar ថ្ងៃទី១៣ ដល់២៥ ខែមិនា ឆ្នាំ២០១០) បានស្នើអោយលេខាធិការដ្ឋាន CITES ធ្វើ៖

*"...ចុះកិច្ចសន្យាជាមួយអ្នកជំនាញដើម្បីរៀបចំសេចក្តីណែនាំក្នុងការផ្តល់ដំបូន្មានទៅកាន់ភាគីពីការប្រើប្រាស់កូដប្រភពដែត្រឹមត្រូវ .... ដែលនឹងមានផ្តល់នៅកាន់គណកម្មការសត្វនិងរុក្ខជាតិសម្រាប់ពិនិត្យនិងផ្តល់មតិ"។*

http://www.cites.org/sites/default/files/eng/cop/16/doc/E-CoP16-48.pdf

លេខាធិការដ្ឋាន CITES តែងតាំង IUCN ដើម្បីធ្វើកិច្ចការនេះ។ របាយការណ៍នេះជាលទ្ធផលនៃកិច្ចការ និងមានគោលបំណងណែនាំភាគី CITES ក្នុងការប្រើប្រាស់កូដប្រភពត្រឹមត្រូវសម្រាប់សត្វដែលចូលក្នុងពាណិជ្ជកម្ម អន្តរជាតិ។

# 2.0 កូដប្រភពបច្ចុប្បន្ន និងប្រព័ន្ធផលិតកម្ម

អត្ថន័យកូដប្រភពដែលបានប្រើប្រាស់នៅទីនេះ ត្រូវបានគេយកចេញពី Resolution Conf. 12.3 (Rev. CoP17) និងវេបសាយ CITES។ សម្រាប់ការពន្យល់បន្ថែមចំពោះអត្ថន័យ សូមមើលសុទ្ធានុក្រម CITES៖

http://www.cites.org/eng/resources/terms/glossary.php

| កូដប្រភព | ពិពណនា | ឧបសម្ព័ន្ធ CITES | និយមន័យ |
|---|---|---|---|
| **W** | ព្រៃ | I, II, III | ពូជសត្វយកពីព្រៃ។ |
| **X** | បរិស្ថានសមុទ្រ | I, II, III | ពូជសត្វយកពីតាមដែនសមុទ្រ ដោយមិនស្ថិតក្រោមយុត្តាធិការរដ្ឋណាមួយ។ |
| **R** | សត្វចិញ្ចឹម | I, II, III | ពូជសត្វដែលបានចិញ្ចឹមនៅក្នុងបរិស្ថានដែលមានការគ្រប់គ្រង យកដូចជាស៊ុតឬកូនសត្វពីក្នុងព្រៃ ដែលជាកន្លែងពួកគេមានលទ្ធភាពរស់រានដល់ពេញវ័យទាប។ |
| **D** | សត្វចិញ្ចឹមបង្កាត់ពូជ ឬរុក្ខជាតិបង្កើតសិប្បនិមិត្ត | I | ឧបសម្ព័ន្ធI សត្វដែលបង្កាត់ពូជនៅក្រោមការថែរក្សាចិញ្ចឹមសម្រាប់គោលបំណងពាណិជ្ជកម្ម ក្នុងការប្រតិបត្តិការដោយរួមមានការចុះបញ្ជីលេខាធិការ ដោយស្របតាម Resolution Conf. 12.10 (Rev. CoP15), និងឧបសម្ព័ន្ធI រុក្ខជាតិបង្កើតសិប្បនិមិត្តសម្រាប់គោលបំណងពាណិជ្ជកម្ម ក៏ដូចជាផ្នែកខ្លះដែលបានបង្កើតមក ហើយត្រូវបាននាំចេញក្រោមបញ្ញត្តិ Article VII, paragraph 4 នៃអនុសញ្ញា។ |
| **A** | រុក្ខជាតិបង្កើតសិប្បនិមិត្ត | I, II, III | រុកខ្សជាតិដែលបានបង្កើតបែបសិប្បនិមិត្តស្របតាម Resolution Conf. 11.11 (Rev. CoP17), ក៏ដូចជាផ្នែកខ្លះដែលបាន បង្កើតមក ត្រូវបាននាំចេញក្រោមបញ្ញត្តិនៃមាត្រា Article VII, paragraph 5 (ពូជរុក្ខជាតិដែលមានចែងក្នុងឧបសម្ព័ន្ធI ដែលត្រូវបានគេបង្កើតមិនមែនសម្រាប់គោលបំណងពាណិជ្ជកម្ម ហើយពូជនោះត្រូវបានគេបញ្ចូលក្នុងឧបសម្ព័ន្ធ II និងIII)។ |
| **C** | រក្សាទុកចិញ្ចឹម | I, II, III | សត្វដែលបានបង្កាត់ពូជនៅក្នុងការថែទាំ ស្របតាម Resolution Conf. 10.16 (Rev.) ក៏ដូចជាផ្នែកខ្លះដែលបានបង្កើតមក នាំចេញក្រោមបញ្ញត្តិនៃមាត្រា VII កថាខណ្ឌ ៥។ |
| **F** | កើតមកក្នុងកន្លែងចិញ្ចឹម | I, II, III | សត្វដែលកើតក្នុងកន្លែងចិញ្ចឹម (F1 និងពូជបន្ទាប់) ដែលមិនបានបំពេញនិយមន័យនៃ "ការបង្កាត់ពូជកន្លែងចិញ្ចឹម" នៅក្នុង Resolution Conf. 10.16 (Rev.) ក៏ដូចជាផ្នែកដែល ចេញពីវា។ |
| **U** | មិនស្គាល់ | I, II, III | ប្រភពនៃសត្វមិនត្រូវបានស្គាល់ ប៉ុន្តែនឹងត្រូវផ្តល់ហេតុផល។ |
| **I** | រឹបអូសបាន ឬប្រមូលបាន | I, II, III | ប្រភេទសត្វដែលត្រូវបានរឹបអូស កូដប្រភពនេះត្រូវប្រើអមជាមួយកូដប្រភពផ្សេងមួយទៀត។ |
| **O** | មុនអនុសញ្ញា | I, II, III | សត្វដែលទទួលបានមុនបញ្ញត្តិអនុសញ្ញាត្រូវបានគេយកមកប្រើប្រាស់។ ប្រសិនបើមានវិញ្ញាបណ្ណប័ត្របញ្ជាក់ដោយអាជ្ញាធរគ្រប់គ្រង នឹងមិនតម្រូវអោយមានលិខិតអនុញ្ញាតផ្សេង ឬវិញ្ញាបណ្ណប័ត្រ ក្រោមអនុសញ្ញាដើម្បីអនុញ្ញាតអោយនាំចេញ នាំចូល ឬនាំចេញជាថ្មីនោះទេ។ |

# 3.0 កូដប្រភពដែលបែកចេញជាពីរ

កូដប្រភពចែកជាពីរផ្សេងគ្នា ត្រូវបានបង្កើតឡើងសម្រាប់ជំនួយភាគីពេលដាក់កូដប្រភពត្រឹមត្រូវសម្រាប់នាំចេញពូជសត្វក្នុងបញ្ជី CITES។ សេចក្តីណែនាំពីរបៀបប្រើគន្លឹះមានដូចខាងក្រោមៈ

1. សម្រាប់ពាណិជ្ជកម្មអន្តរជាតិ មិនថារុក្ខជាតិនិងសត្វ រួមបញ្ចូលទាំងផ្នែករបស់វា ចាប់ផ្តើមដោយ "**X**" ខាងក្រោមទំព័រនេះ។

2. សម្រាប់សំនួរនិមួយៗ ត្រូវឆ្លើយ "មាន" ឬ "គ្មាន" ព្រួញទៅកាន់ប្រអប់សំនួរបន្ទាប់រហូតដល់ចប់ជាមួយនឹងប្រអប់ពោរពេញដោយព័ត៌មួយ។ ប្រអប់ព័ណ៌នោះបង្ហាញពីកូដប្រភព CITES ដែលគួរតែប្រើពេលចេញលិខិតអនុញ្ញាត និងវិញ្ញាបណ្ណប័ត្រសម្រាប់ ពូជមួយ។

3. ប្រអប់ខ្លះមានសញ្ញាផ្កាយ ដែលបញ្ជាអ្នកប្រើប្រាស់ទៅកាន់សេចក្តី ណែនាំបន្ត (អាចឃើញក្នុងផ្នែក ៤.០ ទៅដល់ ៧.០) ដើម្បីកំណត់កូដប្រភព។

4. ប្រសិនបើនៅមិនច្បាស់ កូដប្រភពមួយណាគួរប្រើសម្រាប់ពូជមួយ សូមពិភាក្សាជាមួយលេខាធិការដ្ឋាន CITES។

5. សូមកត់សម្គាល់ផងដែរថាមានករណីលើកលែងពីរពី ហើយមានបញ្ញត្តិពិសេសត្រូវបានអនុវត្តចំពោះបញ្ជីពូជសត្វ CITES - **ភ្ជាប់ជាមួយករណីលើកលែង និងបញ្ញត្តិពិសេសដែលមានផ្តល់ក្នុងផ្នែក៧.០នៃសេចក្តីណែនាំនេះ។**

6. ព័ត៍មានដូចគ្នាត្រូវបានដាក់បង្ហាញក្នុងទម្រង់សំនួរនៅក្នុងឯកសារភ្ជាប់បន្ថែមលើសេចក្តីណែនាំ (សូមមើលទំព័រ១២ "ពីតារាងលំហូរក្នុងទម្រង់កម្រងសំនួរ").


តើពូជនេះមានក្នុងបញ្ជី CITES ទេ?
ឧបសម្ព័ន្ធ (I, II ឬ III)?
គ្មាន
មិនតម្រូវអោយមានលិខិតអនុញ្ញាតនាំចេញទេ
មាន
តើពូជនេះត្រូវបានទិញមុនពេលបញ្ញត្តិក្នុងអនុសញ្ញាត្រូវបានអនុវត្ត?
មាន
កូដប្រភព O –
ពូជនោះមុនអនុសញ្ញា
(តម្រូវអោយមានវិញ្ញាបណ្ណប័ត្របញ្ជាក់ថាមុនអនុសញ្ញា
ទេ
តើពូចនេះគេរឹបអូស ឬប្រមូលបាន?
មាន
កូដប្រភពI –
សត្វដែលរឹបអូសឬប្រមូលបាន (ការនាំចេញត្រូវស្របតាម
Resolution Conf. 17.8)
គ្មាន
តើមានព័ត៍មានគ្រប់គ្រាន់អំពីពូចសត្វដើម្បីសន្មត
ប្រភពវាទេ?
គ្មាន
កូដប្រភព U –
ប្រភពនៃពូជដែលមិនស្គាល់
(អត្ថបទត្រូវអមជាមួយលិខិតអនុញ្ញាតនាំចេញដើម្បីព
ន្យល់ហេតុអ្វីកូដប្រភពនេះត្រូវបានប្រើ)
មាន
តើពូចសត្វនោះយកមកពីបរិស្ថានសមុទ្រ
ដែលមិនស្ថិតក្រោមយុត្តាធិការរដ្ឋណាមួយ
ដូចមានចែងក្នុង Resolution
Conf. 14.6 (Rev. CoP16)?
មាន
កូដប្រភព X –
ពូជដែលមកពីតំបន់សមុទ្រដែលមិនស្ថិត
យុត្តាធិការរដ្ឋណាមួយ
គ្មាន
ចាប់ផ្តើមដោយអក្សរ X ក្រាស់នៅខាងលើឆ្វេងដៃទៅកាន់ទំព័របន្ទាប់

**ចាប់ផ្តើមជាមួយ “X” នៅខាងលើឆ្វេង ហើយដើរតាំព្រួញ**






**ប្រអប់. 1. ការលើកលែងសម្រាប់រុក្ខជាតិធំពីគ្រាប់ពូជ និងលំអងរុក្ខជាតិ**
**[Resolution. Conf. 11.11 [Rev. CoP17]]**

ករណីលើកលែងអាចនឹងផ្តល់អោយបាន និងពូជដែលបង្កើតបែបសិប្បនិម្មិត ប្រសិនបើធំចេញពីគ្រាប់ពូជប្រមូលពីព្រៃ ឬលំអងរុក្ខជាតិប្រសិនបើមាន taxon៖

**a)** **i)** ការបង្កើតបណ្តុះស្តុកបង្ហាញពីការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្ត ពិព្រោះពូជនេះត្រូវការចំណាយពេលច្រើនដើម្បីដល់អាយុបន្តពូជបាន ក៏ដូចជាសម្រាប់ដើមឈើជាច្រើនផងដែរ;

**ii)** គ្រាប់ពូជ ឬលំអងរុក្ខជាតិត្រូវបានប្រមូលពីព្រៃ ហើយដាំក្រោមលក្ខខណ្ឌមានការគ្រប់គ្រងជាមួយនឹងរដ្ឋ ដែលត្រូវតែជាប្រទេសដើមកំណើតនៃគ្រាប់ពូជ ឬលំងរុក្ខជាតិនេះផងដែរ

**iii)** អាជ្ញាធរគ្រប់គ្រងពាក់ព័ន្ធនៅក្នុងរដ្ឋនោះបានកំណត់ពីការប្រមូលគ្រាប់ពូជ ឬលំអងរុក្ខជាតិដែលស្របច្បាប់ និងស្របតាមច្បាប់ជាតិដែលពាក់ព័ន្ធសម្រាប់ការពារនិងអភិរក្សពូជនោះ ហើយ

**iv)** អាជ្ញាធរវិទ្យាសាស្ត្រពាក់ព័ន្ធរបស់រដ្ឋបានកំណត់ថា៖

**A.** ការប្រមូលគ្រាប់ពូជនិងលំអងរុក្ខជាតិដែលមិនអន្តរាយដល់ការរស់រានរបស់ពូជវានៅក្នុងព្រៃ និង

**B.** អនុញ្ញាតការជួញដូរពូជបែបនេះ បានជះឥទ្ធិពលវិជ្ជមានមកកាន់ការអភិរក្សចំនួនព្រៃ។

**b)** ចំពោះការកម្រិតអប្បបរមា ក្នុងការអនុវត្តស្របជាមួយនឹងឃ្លា a) iv) A. និង B.ខាងលើ:

**i)** ការប្រមូលគ្រាប់ពូជនិងលំអងរុក្ខជាតិសម្រាប់គោលបំណងនេះ ត្រូវបានកំណត់ត្រឹមចំនួនដែលអាចអនុញ្ញាតអោយមានកើនចំនួនក្នុងព្រៃ;

**ii)** ចំណែកមួយនៃរុក្ខជាតិដែលបានកើតក្រោមលក្ខខណ្ឌត្រូវបានបង្កើតការដាំ រុក្ខជិតដើម្បីដាំដុះជាមេនៅថ្ងៃអនាគត និងក្លាយជាប្រភពបន្ថែមនៃគ្រាប់ពូជឬលំអងរុក្ខជាតិចេញពីព្រៃ និង

**iii)** មួយផ្នែកនៃរុក្ខជាតត្រូវបានបង្កើតក្រោមលក្ខខណ្ឌ សម្រាប់ដាំវិញនៅក្នុងព្រៃដើម្បីបង្កើនការទទួលបានមកវិញនូវចំនួន ឬដើម្បីបង្កើនពូជជាថ្មីបាត់បង់ទាំងស្រុង និង

**c)** ក្នុងករណីដំណើការកើតកូនកើតចៅ ឧបសម្ព័ន្ធ1 ពូជសម្រាប់គោលដៅពាណិជ្ជកម្មស្ថិតក្រោមលខ្ខខណ្ឌនេះដែលគេបានចុះបញ្ជីជាមួយលេខាធិការដ្ឋាន CITES ដែលស្របតាម Resolution Conf. 9.19 (Rev. CoP15) ស្តីពី សេចក្តីណែនាំសម្រាប់ចុះបញ្ជីនៃការបណ្តុះសម្រាប់នាំចេញរុក្ខជាតិសប្បនិម្មិតដែលមានពូជរីកលូតលាស់ ក្នុងឧបសម្ព័ន្ធ១។.

* រុកជាតិផ្សាំត្រូវបានគេទទួលស្គាល់ថារីកលូតលាស់តែពេលឬស និងបន្សាំយកចេញពីពូជសិប្បនិម្មិតដូចគ្នា។

# 4.0 សេចក្តីណែនាំបន្ថែមពេលប្រើកូដប្រភព R

CITES កំណត់និយមន័យ “ចិញ្ចឹម” ថា ***គឺជាការមើលថែក្នុងបរិស្ថានដែលមានការគ្រប់គ្រងសត្វ មិនថាជាស៊ុត ឬកូនសត្វដែលយកពីព្រៃបើមិនអិញ្ចឹងទេពួកគេអាចនឹងមានលទ្ធភាពរស់ដល់ពេញវ័យតិចតួច។***
បើទោះបីជាមានការកែប្រែអោយកាន់តែលម្អិតក៏ដោយ [Resolution. Conf. 11.16 (Rev. CoP15)]
និយមន័យនៃពាក្យចិញ្ចឹមនៅតែមានពាក្យមិនប្រាកដពីរបី ម៉ាត់ ដែលបើកអោយមានការបកស្រាយ
និងប្រកាសខុសពីប្រភព ប្រសិនបើមិនកំណត់អោយបានច្បាស់ទេ។
ផ្នែកនេះផ្តល់ព័ត៍មានបន្ថែមដើម្បីជំនួយភាគីអោយដាក់កូដប្រភព “R” អោយបានត្រឹមត្រូវ។

**តើអ្វីទៅដែលធ្វើអោយលទ្ធភាពរស់ដល់ពេញវ័យមានលក្ខណៈទាប?**

លទ្ធភាពរស់រានដល់ពេញវ័យ គឺជាកត្តាពិចារណាសំខាន់បំផុត ពេលកំណត់ថាតើពូជ គឺជាពូជដែលអាចចិញ្ចឹម (ដូចពាក្យដែលបានកំណត់បច្ចុប្បន្នដោយភាគី CITES)។ លទ្ធភាពដែលអាចរស់ទាក់ទងទៅនឹងពូជសត្វ យុទ្ធសាស្រ្តប្រវត្តិជីវិត។ ពូជសត្វខ្លះត្រូវបានគេជ្រើសជាពូជ “R”៖ ពួកវាមានកូនច្រើន មានចំនួនតូចទេក្នុងចំណោមកូនទាំងអស់ដែលអាចរស់ដល់ពេញវ័យ។ ពូជសត្វខ្លះជាប្រភេទ “K”៖ ពួកគេមានចំនួនកូនតិចទេ ដែលមួយៗមានលទ្ធភាពដល់ពេញវ័យខ្ពស់។ ឧទាហរណ៍ កន្ធាយសមុទ្រ ក្រពើ ត្រីឆ្អឹង និងសត្វឥតឆ្អឹងខ្នងភាគច្រើន មានប្រភេទ R និងបង្កើតស៊ុតច្រើន ដែលមានចំនួនតិចដែលអាចរស់ដល់ពេញវ័យ។ ចំណែកឯ កូនសត្វដូចជាដំរី និងគោគឺប្រភេទ K ដែលមានលទ្ធភាពរស់ដល់ពេញវ័យ។ ហេតុដូច្នេះ ការដកកូនសត្វប្រភេទ K ចេញពីព្រៃអាចនឹងមានលទ្ធផលល្អសម្រាប់ចំនួនសត្វព្រៃ ជាជាងដកប្រភេទសត្វ R។ ហេតុដូច្នេះ ប្រព័ន្ធផលិតកម្មចិញ្ចឹមសត្វ អាចអនុវត្តបានសម្រាប់ស៊ុត និងកូនពូជសត្វដែលភាគច្រើននៃសត្វទាំងនេះនៅក្នុងព្រៃស្លាប់ដោយសារហេតុផលធម្មជាតិ (ឧទាហរណ៍ សត្វធំស៊ី ជម្ងឺ និងដោយបរិស្ថាន ។ល។

**តើអ្វីទៅដែលធ្វើអោយមាន “ *ការចិញ្ចឹមនៅក្នុងបរិស្ថានដែលមានការគ្រប់គ្រង*”?**

ក្នុងគោលបំណងប្រើប្រាស់កូដប្រភព R អោយបានត្រឹមត្រូវ ពាក្យថា “មើលថែ” គួរតែពាក់ព័ន្ធទៅនឹងកម្រិតនៃការលូតលាស់ ឬអភិវឌ្ឍនៃពូជដែលបានចិញ្ចឹម កំឡុងពេលមើលថែគ្រប់គ្រង ប៉ុន្តែវាមិនចាំបាច់កំណត់ពីរយៈពេលចំណាយគ្រប់គ្រងទេ។ ភាពខុសគ្នានេះមានសារៈសំខាន់ ពិព្រោះភាពខុសគ្នានៃប្រវត្តិជីវិតក្នុងចំណោម taxa។ ឧទាហរណ៍ សត្វឥតឆ្អឹងខ្នងខ្លះអាចនឹងចិញ្ចឹមពីរអាទិត្យក្រោយក្នុងបរិស្ថានបែបគ្រប់គ្រង ដោយសារតែការរីកលូតលាស់វាលឿន។ ផ្ទុយទៅវិញ សត្វល្អូនខ្លះ (ឧទាហរណ៍ អណ្តើកដែលធំយឺត) អាចនឹងតម្រូវអោយមានរយៈពេលយូរដោយស្ថិតក្រោមការគ្រប់គ្រង មុននឹងចាត់ទុកថាចិញ្ចឹម។ នៅពេលកំណត់ថាអ្វីទៅដែលមើលថែក្នុងបរិស្ថានដែលមានការគ្រប់គ្រង អាជ្ញាធរគ្រប់គ្រង ដោយមានការពិភាក្សាជាមួយអាជ្ញាធរវិទ្យាសាស្រ្ត គួរកំណត់ថាតើ៖

1) ទីតាំងមើលថែ សកម្មក្នុងការផ្តល់លក្ខខណ្ឌចាំបាច់សម្រាប់ការរីកលូតលាស់ និងជីវភាពរបស់ពូជសត្វនោះ ទេ (ឧទាហរណ៍ ជម្រកសមរម្យ អាហារ តំហែរទាំបសុពេទ្យ ។ល។) ឬ

2) ទុកពូជសត្វនោះពិចារណាសម្រាប់នាំចេញ.

ប្រសិនបើអាជ្ញាធរគ្រប់គ្រង ពិចារណាថាទីតាំងមួយផ្តល់លក្ខខណ្ឌចាំបាច់សម្រាប់លូតលាស់ និងអភិវឌ្ឍ អិញ្ចឹងពូជសត្វដែលចេញពីទីតាំងនោះអាចនឹងចិញ្ចឹម។ ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើគ្មានលក្ខខណ្ឌបែបនេះទេ ពូជសត្វនោះអាចនឹងជាសត្វព្រៃ។ ទោះជាយ៉ាងណាក៏ដោយ អ្នកគួរសម្គាល់ផងដែរថា ការមើលថែក្នុងបរិស្ថានមានការគ្រប់គ្រង មិនមានន័យថាសត្វនិមួយៗត្រូវគ្រប់គ្រងឃុំរហូតដល់ពេញវ័យដើម្បីអោយសមនឹងពាក្យថាចិញ្ចឹមនោះទេ។

**ការយល់ដឹងពីទីផ្សារ**

ព័ត៍មានដ៏មានតម្លៃមួយពីការណែនាំក្នុងការប្រើប្រាស់កូដប្រភព “R” CITES អោយបានត្រឹមត្រូវ គឺដើម្បីយល់ពីធម្មជាតិ និងអត្តចារិកនៃទីផ្សារដែលពូជមួយបានបង្កើតសម្រាប់ផ្គត់ផ្គង់។ ឧទាហរណ៍ ពូជមួយនាំចេញសម្រាប់លក់សត្វចិញ្ចឹម ដែលជាធម្មតាគេតម្រូវវាជាកូនតូចៗ។ ជាទូទៅពូជទាំងនេះ មិនមានការអភិវឌ្ឍធំដុំទេក្នុងបរិស្ថានដែលមានការគ្រប់គ្រងមុនពេលនាំចេញទៅលក់ ហេតុដូច្នេះមិនទាន់បានចិញ្ចឹមទេ។ ផ្ទុយទៅវិញ សត្វដែលគេនាំចេញ

សម្រាប់សាច់ ឬលក់ស្បែក ជារឿយៗតម្រូវជាសត្វធំ ហើយហេតុដូច្នេះត្រូវបានគេចិញ្ចឹមនៅក្នុងបរិស្ថានដែលមានការគ្រប់គ្រង សម្រាប់រយៈពេលយូរ ដើម្បីអោយទំហំរាងកាយវាធំតាមតម្រូវការទីផ្សារ។

# 5.0 ជំនួយបន្ថែមពេលប្រើកូដប្រភព C

1. នៅពេលវាយតម្លៃពាក្យសុំនាំចេញពូជសត្វដែលមានចែងក្នុង CITES ដែលសុំដោយអ្នកស្នើមថាបានបង្កាត់ពូជ ការពិចារណាបន្ទាប់នឹងជំនួយដោយការបញ្ជាក់ថាតើពូជនោះបានបំពេញតម្រូវការ CITES សម្រាប់ការចិញ្ចឹមបង្កាត់ពូជឬទេ។

2. ដោយបានប្រកាសថាពូជនោះត្រូវបានបង្កាត់ ដោយស្របតាមនិយមន័យក្នុង Resolution Conf. 10.16 (Rev.), ដើម្បីធានាថាជាផលទ្ធផលដាកកូដប្រភពត្រឹមត្រូវ វាចាំបាច់ក្នុងការកំណត់:

   i. ឧបសម្ព័ន្ធមួយណាដែលពូជនេះគេដាក់បញ្ចូល ហើយ

   ii. គោលបំណងនៃការនាំចេញ (ពាណិជ្ជកម្ម ឬមិនពាណិជ្ជកម្ម)។

3. ប្រសិនបើពូជនោះ ស្ថិតក្នុងពូជឧបសម្ព័ន្ធ I ដែលថាបានបង្កាត់ពូជនោះ ហើយការបង្កាត់នោះគឺសម្រាប់គោលបំណងពាណិជ្ជកម្ម សូមពិភាក្សាជាមួយវេបសាយ CITES ដើម្បីកំណត់ថាតើពូជនោះយកពីដំណើការបង្កាត់ពូងដែលមានចុះបញ្ជីនៃការដំណើការបង្កាត់ពូជនៅក្នុងលេខាធិការដ្ឋានឬអត់ http://www.cites.org/eng/common/reg/cb/summary.html

4. ប្រសិនបើគ្មានចម្ងល់ថាតើពូជនោះមកពីដំណើការបង្កាត់ពូជដែលមានចុះបញ្ជី CITES ហើយអត់ អញ្ចឹងសូមយកកូដប្រភព D។

5. ប្រសិនបើគ្មានចម្ងល់ទេ ហើយអ្នកស្នើពាក្យមិនអាចផ្តល់ភស្តុតាងគ្រប់គ្រាន់ដើម្បីបញ្ជាក់ថាពូជនេះ មានដើមកំណើតចេញពីប្រតិបត្តិការដែលមានចុះបញ្ជី CITES សូមកុំដាក់កូដប្រភព D។ ក្នុងលក្ខខណ្ឌបែបនេះ វាចាំបាច់ក្នុងការកំណត់ថាតើ ពូជសត្វនោះពិតជាបានបង្កាត់ក្នុងទីតាំងនោះមែនឬអត់ ប្រមូលផលពីព្រៃ ឬទទួលបានពីប្រភពផ្សេងទៀត។

6. ប្រសិនបើគ្មានភស្តុតាងបញ្ជាក់ពីវត្តមាននៃពូជនោះថាបានបង្កាត់ស្របតាមនិយមន័យក្នុង Resolution Conf. 10.16 (Rev.) នោះទេ អញ្ចឹងសូមមានការប្រុងប្រយ័ត្ន ហើយត្រូវធ្វើការវាយតម្លៃអោយមានលក្ខណៈលម្អិត។

7. នៅក្នុងលក្ខខណ្ឌបែបនេះ ព័ត៍មានសម្រាប់សំនួរខាងក្រោមនឹងជួយកំណត់ថាតើពូជសត្វនោះ អាចចូលក្នុងអត្ថន័យ “បង្កាត់ពូជនៅកន្លែងទុក” ក្នុង Resolution Conf. 10.16 (Rev.) ហេតុដូច្នេះ ធ្វើអោយ អាជ្ញាធរគ្រប់គ្រងធ្វើការសម្រេចចិត្តដោយបានដឹងមុន ថាតើដាក់កូដប្រភព C, F ឬបដិសេធការស្នើនេះ៖

   i. តើមានអាជ្ញាប័ណ្ណក្នុងការបង្កាត់ពូជនេះទេ? ប្រសិនបើប្រតិបត្តិការនេះគ្មានអាជ្ញាប័ណ្ណ ត្រូវសួរពីភាពស្របច្បាប់នៃការនាំចេញ

   ii. ថ្ងៃណាសដែលពូជនិមួយត្រូវបានផ្តល់អាជ្ញាប័ណ្ណដំបូង ឬចុះបញ្ជីដើម្បីប្រតិបត្តិ?

   iii. មានលិខិតអនុញ្ញាតចំនួនប៉ុន្មានក្នុងកំឡុងពេលកន្លងមក ដើម្បីប្រមូលពូជពីព្រៃ ហើយមានប៉ុន្មានក្បាលដែលបានប្រមូលមក ដើម្បីបង្កើនចំនួនសត្វសត្វនោះដោយចិញ្ចឹម?

   iv. តើចំនួនផលិតកម្មប្រចាំឆ្នាំ ហើយយោងតាមយោបល់វិទ្យាសាស្ត្រឯករាជពីអត្តចារិកជីវសាស្ត្រនៃពូជសត្វនោះ តើចំនួននោះអាចទៅរួចទេសម្រាប់ពូជដែលបានរៀបរាប់?

   v. តើមានចំនួនពូជនេះប៉ុន្មានក្បាលដែលគេរក្សាទុកបង្កាត់ពូជ? ហើយមានសត្វញីឈ្មោលពេញវ័យបង្កាត់ពូជបានប៉ុន្មានក្បាលសរុបសម្រាប់ស្តុកមេបា?

   vi. តើទីតាំងនេះត្រូវបានត្រួតពិនិត្យដោយមន្ត្រី មកពីអាជ្ញាធរវិទ្យាសាស្ត្រនិងគ្រប់គ្រង ហើយមានរបាយការណ៍ត្រួតពិនិត្យទេ?

8. ក្នុងករណីដែលមានចម្ងល់ពីសុក្រឹត្យភាពនៃកូដប្រភព ប្រសិនបើចាំបាច់អាជ្ញាធរគ្រប់គ្រងនៃប្រទេសនាំចូលគួរពិភាក្សាជាមួយ អាជ្ញាធរវិទ្យាសាស្ត្រនៃប្រទេសនាំចេញ ដើម្បីកំណត់ពីពូជសត្វនោះគេឧស្សាហ៍បង្កាត់ឬទេ

ជាមួយនឹងយុត្តាធិការរបស់អាជ្ញាធរគ្រប់គ្រងរបស់ប្រទេសនាំចេញ។ ក្នុងករណីនៅមានចម្ងល់ បញ្ហានេះគួរយកទៅដល់លេខាធិការដ្ឋាន CITES។

# 6.0 និយមន័យដែលពាក់ព័ន្ធ

CITES Glossaryអត្ថន័យទាំងអស់នេះត្រូវបានយកចេញពីវេបសាយ CITES។ សម្រាប់ការពន្យល់ពាក្យបន្ថែម សូមមើលសទ្ទានុក្រម CITES http://www.cites.org/eng/resources/terms/glossary.php

| | |
|---|---|
| **ការលូតលាស់សិប្បនិមិត្ត (សម្រាប់រុក្ខជាតិ)** | ពូជរុក្ខជាតិដែល:<br>• លូតលាស់ក្រោមលក្ខខណ្ឌដែលមានការគ្រប់គ្រង ហើយ<br>• កើតចេញពីគ្រាប់ពូជ ការកាត់ ការបំបែក ជាលិកាស្បែកឬជាលិការុក្ខជាតិផ្សេង លម្អងរុក្ខជាតិ ឬបន្សាំ ដោយមិនថាស្ថិតក្រោមការលើកលែងពីបញ្ញត្តិនៃ អនុសញ្ញា ឬលូតចេញមកពីដើមមេរបស់វា;<br>• ឬ សម្រាប់ taxa ដែលធ្វើពី agarwood លូតពីគ្រាប់ពូជ បានជាគ្រាប់ពូជវិញ កូនឈើ កាត់ បន្សាំ marcoting/ស្រទាប់ខ្យល់ ការបែងចែក ជាលិការុក្ខជាតិ ឬ កូនឈើផ្សេងដែលយកចេញពីព្រៃ ឬរីកលូតលាស់ពីស្តុកមេវា ដែលស្របតាម និយមន័យ 'ធ្វើកសិកម្មស្តុករុក្ខជាតិមេ' នៅក្នុង Resolution Conf. 11.11 (Rev. CoP17). |
| **បង្កាត់ពូនៅក្នុងកន្លែងចិញ្ចឹម (សម្រាប់សត្វ)** | សត្វដែលកើតមក ឬបើមិនដូច្នេះផលិតបានក្នុងបរិស្ថានដែលមានការគ្រប់គ្រង ក្នុងករណីប្រសិនបើ៖<br>i) មេបាវរួមភេទ ឬផ្ទេរទឹកកាមក្នុងបរិស្ថានដែលមានការគ្រប់គ្រង (ប្រសិនបើ បង្កើតតាមផ្លូវភេទ) ឬមេបារបស់វាស្ថិតក្នុងបរិស្ថានដែលមានការគ្រប់គ្រង នៅពេលដែលការអភិវឌ្ឍរបស់កូនចាប់ផ្តើម (បង្កើតដោយគ្មានការរួមភេទ)<br>ii) ស្តុកសម្រាប់បង្កាត់ពូជ ដើម្បីបំពេញទៅតាមបំណងរបស់អាជ្ញាធររាជរដ្ឋាភិបាលមានសមត្ថកិច្ចនៃប្រទេសនាំចេញ៖<br>a) ត្រូវបានបង្កើតស្របតាមបញ្ញត្តិរបស់ CITES និងច្បាប់ជាតិដែលពាក់ព័ន្ធ និងក្នុងលក្ខខណ្ឌមិនអន្តរាយដល់ភាពរស់រាននៃពូជនេះនៅក្នុងព្រៃ។<br>b) ត្រូវរក្សាដោយគ្មានការណែនាំពីពូជនោះថាមកពីព្រៃ ករណីលើកលែងតែម្តងម្កាលបន្ថែមសត្វ ស៊ុត ឬហ្គាម៉ែត ដោយស្របតាមបញ្ញត្តិរបស់ CITES និងច្បាប់ជាតិដែលពាក់ព័ន្ធ និងក្នុងលក្ខខណ្ឌមិនអន្តរាយដល់ការរស់នៅរបស់ពូជសត្វនៅក្នុងព្រៃ ដូចដែលបានប្រឹក្សាដោយអាជ្ញាធរវិទ្យាសាស្ត្រ<br>1. ការពារ និងបន្ធូរបន្ថយការបង្កាត់ពូជដែលអន្តរាយ ជាមួយនឹងទំហំនៃការកំណត់បន្ថែមដោយភាពចាំបាច់សម្រាប់ហ្សែនថ្មី<br>2. បោះបង់សត្វដែលរឹបអូសស្របតាម Resolution Conf. 17.8; ឬ<br>3. ក្នុងករណីលើកលែង សម្រាប់ប្រើវាជាស្តុកបង្កាត់ពូជ និង<br>c)<br>1. បានបង្កើកូនជំនាន់ទីពីរ (F2) ឬជំនាន់ក្រោយៗទៀត (F3, F4, etc.) នៅក្នុងបរិស្ថានដែលមានការគ្រប់គ្រង; ឬ<br>2. ត្រូវបានគ្រប់គ្រងតាមបែបដែលបានបង្ហាញ ដើម្បីមានលទ្ធភាពគួរអោយទុកចិត្តបានក្នុងបង្កើកូនជំនាន់ទីពីរនៅក្នុងបរិស្ថានដែលមានការគ្រប់គ្រង។ |
| **ស្តុកបង្កាត់ពូជ** | បណ្តុំនៃសត្វប្រើសម្រាប់បង្កាត់ពូជនៅក្នុងប្រតិបត្តិការបង្កាត់ពូជសត្វចិញ្ចឹម |
| **បរិស្ថានដែលមានការគ្រប់គ្រង (សម្រាប់សត្វ) /<br><br>បរិស្ថានដែលមានការគ្រប់គ្រង (សម្រាប់រុក្ខជាតិ)** | សម្រាប់សត្វ៖ បរិស្ថានដែលរៀបចំសម្រាប់គោលបំណងបង្កើតពូជសត្វមួយ ដែលមានព្រំដែនបង្កើតមកដើម្បីការពារសត្វ ស៊ុត ឬហ្គាម៉ែតនៃពូជសត្វនោះពីការចូល និងចាកចេញពីវា ហើយអត្តចារិកធម្មតាដែលអាចរួមមាន ដោយមិនកំណត់ត្រឹម៖ ផ្ទះសិប្បនិម្មិត ការបោះចោលកាកសំណល់ តំហែរទាំងសុខភាព ការការពារពីសត្វដែលអាចស៊ីវា និងផ្គត់ផ្គង់អាហារសិប្បនិម្មិត។<br>សម្រាប់រុក្ខជាតិ៖ បរិស្ថានដែលមិនមែនធម្មជាតិដែលត្រូវបានរៀបចំដោយការអន្តរាគមន៍របស់មនុស្សនោះ សម្រាប់គោលបំណងផលិតរុក្ខជាតិ។ អត្តចារិកទូទៅនៃលក្ខខណ្ឌដែលមានការគ្រប់គ្រង សម្រាប់បង្កើតរុក្ខជាតិនោះ អាចរួមមានតែមិនកំណត់ត្រឹម៖ ការភ្ជួររាស់ដី បង្កកំណើត ការត្រួតពិនិត្យស្មៅនិងសត្វល្អិត ប្រព័ន្ធធារាសាស្ត្រឬបណ្តុះ កូនដូចជាដាក់ក្នុងផើង ឬការការពារពីអាកាសធាតុ។ |

| | |
|---|---|
| **ស្តុកមេដែលបានដាំ (សម្រាប់រុក្ខជាតិ)** | ក្រុមរុក្ខជាតិដែលលូតលាស់ក្រោមលក្ខខណ្ឌដែលមានការគ្រប់គ្រង ដែលត្រូវបានគេប្រើសម្រាប់បន្តពូជ ហើយចាំបាច់ត្រូវតែមានការពេញចិត្តដោយអាជ្ញាធរប្រទេសនាំចេញ ដែល CITES ចាត់តាំង:<br>• បង្កើតស្របតាមបញ្ញត្តិនៃ CITES និងច្បាប់ជាតិដែលពាក់ព័ន្ធ ហើយក្នុងក្របខ័ណ្ឌដែលមិនអន្តរាយដល់ការរស់រានរបស់ពូជវានៅក្នុងព្រៃ ហើយ<br>• រក្សាចំនួនគ្រប់គ្រាន់សម្រាប់ការបង្កើន ហេតុដូច្នេះដើម្បីកាត់បន្ថយឬបំបាត់ភាពចាំបាច់នៃការយកពីព្រៃ ដោយការយកនោះកើតឡើងក្នុងករណីលើកលែងដោយសារតែមានចំនួនកំណត់ចាំបាច់រក្សា ភាពរឹងមាំ និងផលិតភាពនៃស្តុកមេដែលដាំ។ |

# 7.0 សេចក្តីណែនាំបន្ថែម

**សេចក្តីណែនាំពីការអនុញ្ញាត និងវិញ្ញាបណ្ណប័ត្រ:**
http://www.cites.org/eng/disc/text.php#VI

**សេចក្តីណែនាំពីការលើកលែង និងបញ្ញត្តិពិសេសផ្សេងៗទាក់ទងនឹងពាណិជ្ជកម្ម:**
http://www.cites.org/eng/disc/text.php#VII

**សេចក្តីណែនាំពី Resolution Conf. 12.3 (Rev. CoP17) - ការអនុញ្ញាត និងវិញ្ញាបណ្ណប័ត្រ:**
https://cites.org/sites/default/files/document/E-Res-12-03-R17.pdf

**Annex**

# តារាងលំហូរក្នុងទម្រង់កម្រងសំនួរ

1. តើពូជសត្វនោះមានចែងក្នុងឧបសម្ព័ន្ធ CITES (I, II or III)?

មាន ........................................................................................................ទៅសំនួរទី 2

គ្មាន.....................................................................មិនតម្រូវអោយមានលិខិតអនុញ្ញាតនាំចេញ CITES

2. តើបានទិញពូជសត្វនេះមុនការចាប់អនុវត្តបញ្ញត្តិអនុសញ្ញានេះ?

មាន ........................................................................................................កូដប្រភព O

គ្មាន........................................................................................................ទៅសំនួរទី ៣

3. តើសត្វនេះត្រូវបានគេរឹបអូស ឬចាប់? ការនាំចេញត្រូវស្របតាម [Resolution. Conf. 17.8]

មាន........................................................................................................កូដប្រភព I

គ្មាន........................................................................................................ទៅសំនួរទី ៤

4. តើមានព័ត៌មានគ្រប់គ្រាន់អំពីពូជសត្វនោះ ដើម្បីសន្និដ្ឋានពីប្រភពរបស់វា?

មាន........................................................................................................ទៅសំនួរទី ៥

គ្មាន........................................................................................................កូដប្រភព U

5. តើពូជសត្វនោះយកមកពីបរិស្ថានសមុទ្រដែលមិនស្ថិតក្រោមយុត្តាធិការរដ្ឋណាមួយទេមែនទេ?

មាន........................................................................................................កូដប្រភព X

គ្មាន........................................................................................................ទៅកាន់សំនួរទី ៦

6. តើពូជនោះជារុក្ខជាតិ ឬជាសត្វ?

សត្វ ........................................................................................................ទៅកាន់សំនួរទី ៧

រុក្ខជាតិ ........................................................................................................ទៅកាន់សំនួរទី ២១

7. តើពូជនោះយកពីព្រៃមែនទេ?

មែន.......................................................................................................................ទៅកាន់សំនួរទី 8

ទេ .......................................................................................................................ទៅកាន់សំនួរទី 13

8. តើពូជសត្វនោះយកពីព្រៃជាស៊ុត ឬជាកូនដែលមានលទ្ធភាពទាបក្នុងរស់រានដល់ពេញវ័យ?

មែន.......................................................................................................................ទៅកាន់សំនួរ 9

ទេ .......................................................................................................................កូដប្រភព W

9. តើពូជសត្វនោះត្រូវបានចិញ្ចឹមក្នុងបរិស្ថានដែលមានការគ្រប់គ្រង?

មែន........................................ ..........................................................................សូមទៅកាន់សំនួរទី 10

ទេ .......................................................................................................................កូដប្រភព W

10. តើពូជសត្វនោះបានផ្ទេរទៅឧបសម្ព័ន្ធ II ហើយកត់ថាស្របតាម [Resolution Conf. 11.16 (Rev. CoP15)]?

មែ.......................................................................................................................កូដប្រភព R

ទេ.......................................................................................................................ទៅកាន់សំនួរទី11

11. តើពូជសត្វនោះមាននៅក្នុងឧបសម្ព័ន្ធ CITES II ឬ III?

មាន.......................................................................................................................កូដប្រភព R

គ្មាន.......................................................................................................................ទៅកាន់សំនួរទី 12

12. តើពូជសត្វនោះបានបំពេញតម្រូវការ ក្រោមមាត្រា III នៃអនុសញ្ញាឬទេ?

មាន .......................................................................................................................កូដប្រភព W

គ្មាន.......................................................................................................................មិនត្រូវធ្វើការនាំចេញទេ

**13. តើពូជនេះកើតចេញមកពីមេបាវាដែលបានរួមភេទ ឬតាមរយៈការផ្ទេរទឹកកាមនៅក្នុងបរិស្ថានដែល មានការគ្រប់គ្រង (បង្កើតដោយរួមភេទ) ឬមេបាវាស្ថិតក្រោមបរិស្ថានដែល មានការគ្រប់គ្រង កំឡុងពេលអភិវឌ្ឍរបស់កូនចាប់ផ្តើម (បង្កើតដោយមិនរួមភេទ)?**

**បាទ ..................................................................................................................ទៅកាន់សំនួរទី 15**

**ទេ ..................................................................................................................ទៅកាន់សំនួរទី 14**

**14. តើពូជសត្វនេះកើតក្នុងកន្លែងមើលថែ ក្នុងបរិដ្ឋានដែលមានការគ្រប់គ្រង?**

**មាន ..................................................................................................................កូដប្រភព F**

**គ្មាន ..................................................................................................................កូដប្រភព W**

**15. តើស្តុកសម្រាប់បង្កាត់ពូជនេះ បង្កើតឡើងស្របតាមបញ្ញត្តិ CITES និងច្បាប់ជាតិដែលពាក់ព័ន្ធ និងក្នុងន័យមិនអន្តរាយដល់ការរស់រានរបស់ពូជនេះនៅក្នុងព្រៃ?**

**បាទ ..................................................................................................................ទៅសំនួរទី ១៦**

**ទេ ..................................................................................................................កូដប្រភព F**

**16. តើស្តុកបង្កាត់ពូជនេះរក្សាដោយមិនមានការណែនាំពីពូជសត្វនេះមកពីព្រៃ លើកលែងតែមានសត្វថ្មី ស៊ុតហ្គាម៉េត ស្របតាម CITES ច្បាប់ជាតិដែលពាក់ព័ន្ធ ហើយក្នុងន័យដែលមិនអន្តរាយដល់ការរស់រាន សត្វក្នុងព្រៃ?**

**បាទ ..................................................................................................................ទៅកាន់សំនួរទី 17**

**ទេ ..................................................................................................................កូដប្រភព F**

**17. តើស្តុកដែលបង្កាត់ពូចបង្កើតកូនជំនាន់ទីពីរ (F2) ឬជំនាន់បន្ទាប់ៗ (F3, F4, ។ល។) នៅក្នុងបរិស្ថានដែលមានការគ្រប់គ្រង ឬគ្រប់គ្រងក្នុងន័យបង្ហាញពីលទ្ធភាពក្នុងការបង្កើតកូនជំនាន់ពីរក្នុងបរិស្ថានដែលមានការគ្រប់គ្រង?**

**បាទ ..................................................................................................................សត្វនេះត្រូវបានបង្កាត់ក្នុងកន្លែងចិញ្ចឹមy**

**ទេ ..................................................................................................................កូដប្រភព F**

**18. តើឧបសម្ព័ន្ធមួយណានៃ CITES មានកត់ពូជនេះ?**

**ឧបសម្ព័ន្ធ I ........................................................................................ទៅកាន់សំនួរទី 19**

**ឧបសម្ព័ន្ធ II ឬ III ........................................................................................កូដប្រភព C**

**19. តើពូជនេះបានបង្កាត់សម្រាប់គោលបំណងពាណិជ្ជកម្ម?**

**មែន........................................................................................ទៅសំនួរទី 20**

**ទេ ........................................................................................កូដប្រភព C**

**20. តើពូជនេះត្រូវបានបង្កាត់នៅកន្លែងដំណើការដែលបានចុះបញ្ជី CITES?**

**មែ........................................................................................កូដប្រភព D**

**ទេ........................................................................................មិនគួរមានការនាំចេញទេ**

**21. តើពូជនេះលូតលាស់ក្រោមលក្ខខណ្ឌមានការគ្រប់គ្រង?**

**មែន........................................................................................ទៅកាន់សំនួរទី 21**

**ទេ........................................................................................កូដប្រភព W**

**22. តើពូជនេះកើតចេញពីគ្រាប់ពូជ ការកាត់ ការបែង ជាលិកាឬស ឬជាលិការុក្ខជាតិផ្សេងៗ លំអងផ្កា ឬការរីកលូតលាស់ផ្សេងៗដែលកើតចេញពីស្តុកមេ ស្របតាមឃ្លា 1b) នៃ [Resolution Conf. 11.11 (Rev. CoP17)]?***

**មែន........................................................................................ទៅកាន់សំនួរទី 26**

**ទេ........................................................................................ទៅកាន់សំនួរទី 23**

**23. តើពូជដែលបានធំចេញពីគ្រប់ពូជព្រៃ ឬលំអងផ្កា ស្របតាមករណីលើកលែងក្នុង [Resolution Conf. 11.11 (Rev. CoP17)] ឬទេ?**

**បាទ ........................................................................................ទៅកាន់សំនួរទី 26**

**ទេ ........................................................................................ទៅកាន់សំនួរទី 24**

**24. តើពូជនេះផ់ចេញពីការកាត់ ឬការបំបែក?**

| | |
|---|---|
| មែន........................................................................................................... | ទៅកាន់សំនួរទី 25 |
| មិនមែន........................................................................................................ | កូដប្រភពE W |

**25. តើការកាត់ ការបែងចែកយកចេញពីរុក្ខជាតិព្រៃ គេមិនចាត់ទុកជាការរីកដុះដាលស្លកមេទេ?**

| | |
|---|---|
| មែន........................................................................................................... | កូដប្រភព W |
| ទេ.............................................................................................................. | ទៅកាន់សំនួរទី 26 |

**26. តើឧបសម្ព័ន្ធមួយណាក្នុង CITES ដែលពូចនេះបានចុះឈ្មោះ?**

| | |
|---|---|
| ឧបសម្ព័ន្ធ I .............................................................................................. | ទៅកាន់សំនួរទី 27 |
| ឧបសម្ព័ន្ធ II ឬ III ........................................................................................ | កូដប្រភព A |

**27. តើពូជសត្វនេះត្រូវបានគេចិញ្ចឹមសម្រាប់គោលបំណងពាណិជ្ជកម្ម?**

| | |
|---|---|
| បាទ.......................................................................................................... | ទៅកាន់សំនួរទី 28 |
| ទេ ............................................................................................................ | ប្រភពកូដ A |

**28. តើពូជនេះត្រូវបានគេបណ្តុះសិប្បនិម្មិតនៅកន្លែងបណ្តុះចែលបានចុះបញ្ជី CITES?**

| | |
|---|---|
| មាន........................................................................................................... | កូដប្រភព D |
| គ្មាន.......................................................................................................... | កូដប្រភព A |

* រុកជាតិផ្សាំត្រូវបានគេទទួលស្គាល់ថារីកលូតលាស់តែពេលឬស និងបន្សាំយកចេញពីពូជសិប្បនិម្មិតដូចគ្នា។